THE SCHOOL DISTRICT OF
PHILADELPHIA

**William R. Hite, Jr., Ed.D.**
ស្នងការ

**ស្នងការដ្ឋាន**
440 North Broad Street
Philadelphia, PA 19130

ថ្ងៃទី5 ខែមេសា ឆ្នាំ2021

ក្រុមគ្រួសារមណ្ឌលសិក្សាធិការជាទីរាប់អាន។

ខ្ញុំមានក្តីសោមនស្សរីករាយ សូមជម្រាបថា សហព័ន្ធគ្រូបង្រៀននៃទីក្រុង Philadelphia (PFT) បានបញ្ចប់ការត្រួតពិនិត្យការត្រៀមរៀបចំសម្រាប់សាលារៀនទាំង 23 ដែលនៅសេសសល់ដែលចាំបាច់ត្រូវទទួលបានការអនុញ្ញាតសម្រាប់ការអនុវត្តផែនការសិក្សាបែបចម្រុះដំណាក់កាលទី II របស់ខ្លួន។ សម្រាប់ដំណាក់កាលទីII សិស្សពីថ្នាក់ទី3 ដល់ថ្នាក់ទី5 និងសិស្សដែលមានតម្រូវការស្មុគស្មាញពីថ្នាក់ទី6 ដល់ថ្នាក់ទី8 ដែលក្រុមគ្រួសាររបស់ពួកគេជ្រើសរើសយកគំរូការសិក្សាបែបចម្រុះ នឹងផ្ទេរទៅការសិក្សារួមបញ្ចូលគ្នារវាងការសិក្សានៅសាលារៀនដោយផ្ទាល់និងការសិក្សាតាមប្រព័ន្ធឌីជីថលរៀងរាល់សប្តាហ៍ ដោយផ្អែកលើកាលវិភាគដែលបានកំណត់ ចាប់ផ្តើមពីថ្ងៃចន្ទ ទី26 ខែមេសា។  បុគ្គលិកទាំងអស់ដែលគាំទ្រដល់ថ្នាក់ទី3 ដល់ថ្នាក់ទី8 នឹងត្រឡប់ទៅកាន់អគារសាលារៀនវិញនៅថ្ងៃចន្ទ ទី12 ខែមេសា។

សាលារៀនទាំង 23 ដែលទទួលបានការអនុញ្ញាតមានដូចជា៖

| | | |
|---|---|---|
| AMY at James Martin | Feltonville Arts & Sciences MS | Philadelphia Learning Academy - North |
| AMY Northwest MS | Feltonville Intermediate School | Philadelphia Juvenile Justice Service Center |
| Baldi MS | Girard Academic Music Program (GAMP) | Science Leadership Academy at Beeber |
| Roberto Clemente MS | Warren G. Harding MS | Tilden MS |
| Russell H. Conwell MS | Hill-Freedman World Academy | General Louis Wagner MS |
| Carver Engineering & Science HS | Julia R. Masterman HS | Grover Washington Jr. MS |
| Crossroads Accelerated Academy | Middle Years Alternative (MYA) | Woodrow Wilson MS |
| Crossroads Academy at Hunting Park | Penn Treaty HS | |

ដើម្បីស្វែងយល់បន្ថែមអំពីកម្រិតសុវត្ថិភាពទាំងអស់ដែលយើងបានដាក់ឲ្យដំណើរការដើម្បីការពារសុខភាពនិងសុខុមាលភាពរបស់មនុស្សគ្រប់គ្នានៅក្នុងសាលារៀនរបស់យើង សូមចូលទៅកាន់ philasd.org/aes។ ប្រសិនបើអ្នកនៅមានសំណួរ អ្នកអាចទូរសព្ទមកខ្សែទូរសព្ទបន្ទាន់របស់យើងសម្រាប់គ្រួសារដែលនិយាយភាសាអង់គ្លេស តាមរយៈលេខ 215-400-5300 ឬស្វែងរកខ្សែទូរសព្ទបន្ទាន់ជាភាសាផ្សេងទៀត នៅទីនេះ។ ខ្សែទូរសព្ទបន្ទាន់ដំណើរការពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹក ដល់ម៉ោង 4:30 ល្ងាច។

សូមអរគុណដល់ការបន្តការអត់ធ្មត់របស់អ្នក ស្របពេលដែលយើងកែលម្អកិច្ចការដ៏សំខាន់នេះឆ្ពោះទៅរកការបើកដំណើរការអគារសាលារៀនរបស់យើងសាឡើងវិញប្រកបដោយសុវត្ថិភាព។ យើងទន្ទឹងរង់ចាំស្វាគមន៍សិស្សានុសិស្សកាន់តែច្រើនបន្ថែមទៀតក្នុងការត្រឡប់ចូលរៀនវិញក្នុងថ្នាក់ដោយផ្ទាល់នៅសប្តាហ៍ខាងមុខ។

ដោយសេចក្តីគោរពរាប់អាន

William R. Hite Jr., Ed.D.
ស្នងការ
មណ្ឌលសិក្សាធិការនៃក្រុង Philadelphia